# ជំពូក ២៦

*ធាតុចនា ព្រះជាម្ចាស់បញ្ជាក់ការតាំងសញ្ញាជាមួយនឹងអ៊ីសាក*
*អ៊ីសាកភរគេពីដំណើររេបិកា អ៊ីសាកទៅនៅស្រុកកេរ៉ា*
*អ៊ីសាកឡើងទៅស្រុកបៀរ-សេបា*

រឿងក្នុងជំពូកនេះ មិនធ្វើអោយខ្ញុំមានចិត្តរីករាយទេ ពីព្រោះអ៊ីសាកគ្រាន់តែដើរជីកអណ្តូងតែពាសប៉ុណ្ណោះ។ បើជំពូកនេះមិនសូវមានន័យមែន តើហេតុអ្វីបានជាព្រះជាម្ចាស់អោយពួកហោរាព្រះអង្គសរសេរទុកមក? ព្រះអង្គច្បាស់ជាចង់អោយយើងដឹងរឿងអ្វីមួយជាពិតប្រាកដ។ ក្នុងជំពូក២៦នេះ មានបង្កប់អត្ថន័យជ្រៅជ្រះអំពីកិច្ចការខាងព្រលឹងវិញ្ញាណ។ គ្រប់ទាំងបទគម្ពីរសុទ្ធតែមានប្រយោជន៍ បានជាសាវ័កប៉ូលលោកមានប្រសាសន៍យ៉ាងដូច្នេះថា "ដ្បិតអស់ទាំងសេចក្តីដែលបានចែងទុកមកជាមុននោះបានចែងសំរាប់នឹងបង្រៀនដល់យើងរាល់គ្នា ដើម្បីឱ្យយើងបានសេចក្តីសង្ឃឹមដោយសេចក្តីអត់ធន់នឹងសេចក្តីកំសាន្តចិត្តដោយសារគម្ពីរ" (រ៉ូម ១៥:៤)។

ជំពូក២៦នេះ មិនមែនគ្រាន់តែបង្រៀនយើងពីសេចក្តីអត់ធ្មត់តែមួយមុខប៉ុណ្ណោះទេ ថ្វីដ្បិតយើងគ្រប់រូបត្រូវការសេចក្តីនោះដោយខានមិនបាន។ ព្រះអង្គមិនមែនដាក់ល័ក្ខខ័ណ្ឌថា ទាល់តែយើងអត់ធ្មត់ ទើបព្រះជាម្ចាស់អាចប្រើប្រាស់យើងកើតនោះឡើយ។ ព្រះជាម្ចាស់អាចប្រើប្រាស់មនុស្សដែលខ្វះសេចក្តីអត់ធ្មត់ ដូចជាលោក

អ័ប្រាហាំ ដូចជាលោកយ៉ាកុប និងក្សត្រដាវីឌជាដើម។ ជីវិតរបស់លោកអ៊ីសាកបន្សល់ទុកអោយយើងនូវមេរៀនយ៉ាងល្អច្រើនណាស់ សម្រាប់ជីវិតយើងសព្វថ្ងៃនេះ។ "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅដំរង់ នឹងការបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីឱ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ" (២ធីម៉ូថេ៣:១៦-១៧)។

ព្រះជាម្ចាស់បានបញ្ជាក់ការតាំងសញ្ញារបស់ទ្រង់ជាមួយអ៊ីសាក ដែលត្រូវជាកូនសម្លាញ់របស់លោកអ័ប្រាហាំ។ បន្ទាប់មកទៀតយើងឃើញសេចក្តីនៅក្នុងជំពូក២៦នេះថា លោកអ៊ីសាកបានជំពប់លើបាបដដែល ដែលឪពុកលោកបានប្រព្រឹត្តិកាលនៅរស់នៅឡើយ។

ជាទីបញ្ចប់នៃជំពូកនេះ យើងឃើញលោកអ៊ីសាកបានជីកអណ្តូងជាច្រើននៅក្នុងស្រុកកេរ៉ា។ ថ្វីដ្បិតដំណើររឿងនៅក្នុងជំពូក២៦នេះ មើលទៅហាក់ដូចជាមិនសូវមានរឿងអ្វីដែលធ្វើអោយយើងចាប់អារម្មណ៍ខ្លាំងក៏ដោយ ក៏ជំពូកនេះ មានបង្កប់សេចក្តីពិត សម្រាប់អោយយើងទាំងអស់គ្នាយកមកប្រើប្រាស់នៅក្នុងជីវិតរបស់យើងសព្វថ្ងៃនេះបានជាស្ថានពរ។

## ព្រះជាម្ចាស់បញ្ជាក់ការតាំងសញ្ញារបស់ទ្រង់ជាមួយនឹងអ៊ីសាក

**សម័យនោះ មានកើតអំណត់នៅក្នុងស្រុក ផ្សេងពីអំណត់ជាន់មុនដែលកើតមាននៅជំនាន់អ័ប្រាហាំ ហើយអ៊ីសាកគាត់ទៅឯអ័ប៊ីម៉្លាឡិច ជាស្តេចសាសន៍ភីលីស្ទីននៅកេរ៉ា (លោកុ.២៦:១)។**

អំណត់នេះ ជាអំណត់លើកទីពីរហើយនៅក្នុងទឹកដីកាណាន។ អំណត់លើកទីមួយកើតឡើងក្នុងជំនាន់លោកអ័ប្រាហាំ និងលោកឡុតដែលបណ្តាលអោយលោកទាំងពីរធ្វើដំណើរចុះទៅប្រទេសអេស៊ីព្ទ។

**នោះព្រះយេហូវ៉ាលេចមកឯគាត់មានបន្ទូលថា កុំឱ្យចុះទៅឯស្រុកអេស៊ីព្ទឡើយ ចូរឯងនៅក្នុងស្រុកដែលអញនឹងប្រាប់ឯងវិញ (លោកុ.២៦:២)។**

ហេតុអ្វីបានជាព្រះជាម្ចាស់ហាមមិនអោយអ៊ីសាកចុះទៅប្រទេសអេស៊ីព្ទ? ព្រះអង្គហាមប្រាមបែបនោះ ពីព្រោះព្រះអង្គមិនចង់អោយអ៊ីសាកធ្វើបាបដដែល ដូចជាឪពុករបស់លោកបានធ្វើបាបនៅក្នុងស្រុកអេស៊ីព្ទនោះឡើយ។ ចំណុចត្រង់នេះសបញ្ជាក់អោយយើងឃើញថា ឪពុកធ្វើយ៉ាងណាកូនក៏ធ្វើយ៉ាងនោះ។ នៅក្នុងន័យនេះស្លឹកឈើពិតមិនជ្រុះឆ្ងាយពីគល់មែន! អំពើបាបរបស់ឪពុកបានឆ្លងមកកូនខ្លួនជាពិតប្រាកដ។ ជាធម្មតាកូនជំនាន់ក្រោយតែងតែប្រព្រឹត្តិកំហុសដដែលដូចឪពុកធ្លាប់ធ្វើ

កំហុសពីមុនមកដែរ លើកលែងតែមានអន្តរាគមន៍ពីអ្វីមួយដែលជួយអោយអ្នកទាំងពីរក្រុមនោះអាចប្រព្រឹត្តិខុសគ្នាបាន។

ព្រះជាម្ចាស់ហាមប្រាមដល់លោកអ៊ីសាកនៅក្នុងពេលស្រុកមានអំណត់នេះថា កុំអោយចុះទៅអេស៊ីព្ទឡើយ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានបញ្ជាក់ការតាំងសញ្ញារបស់ទ្រង់ដែលបានធ្វើជាមួយនឹងលោកអ័ប្រាហាំ ដើម្បីអោយលោកអ៊ីសាកបានដឹងផង។

> **ចូរសំណាក់នៅក្នុងស្រុកនេះចុះ នោះអញនឹងនៅជាមួយនឹងឯង ព្រមទាំងឱ្យពរផង អញនឹងឱ្យស្រុកទាំងនេះដល់ឯងនឹងពូជឯង ហើយអញនឹងសំរេចតាមសេចក្តីសម្បថ ដែលអញបានស្បថនឹងអ័ប្រាហាំឪពុកឯង អញនឹងចំរើនពូជឯងឱ្យបានដូចជា ផ្កាយនៅលើមេឃ ហើយនឹងឱ្យស្រុកទាំងនេះទៅពូជឯង រួចគ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរ ដោយសារពូជឯង (លោកុ.២៦: ៣-៤)។**

ព្រះជាម្ចាស់មានបន្ទូលទៅកាន់អ៊ីសាកថា "កុំឱ្យចុះទៅស្រុកអេស៊ីព្ទឡើយ... អញនឹងសំរេចតាមសេចក្តីសម្បថដែលអញបាន ស្បថនឹងអ័ប្រាហាំឪពុកឯង"។ នៅក្នុងការតាំងសញ្ញានេះ ព្រះអម្ចាស់បញ្ជាក់ថា មានសេចក្តីសន្យាបីយ៉ាង ទីមួយគឺឱ្យស្រុក "អញនឹងឱ្យស្រុកទាំងនេះដល់ឯងនឹងពូជឯង" ទីពីរគឺអោយនគរមួយ "អញនឹងចំរើនពូជឯងបានដូចជាផ្កាយនៅលើមេឃ"។ រីឯទីបីវិញ គឺព្រះអង្គសន្យាថាអ៊ីសាកជាទី

បញ្ចេញព្រះពរ “គ្រប់ទាំង សាសន៍នៅផែនដីនឹងបានពរដោយសារពូជឯង”។

**ពីព្រោះអ័ប្រាហាំបានស្តាប់តាមពាក្យអញ ព្រមទាំងរក្សាបញ្ញើនឹងបញ្ញត្ត ហើយច្បាប់ នឹងក្រិត្យវិន័យរបស់អញ (លោកុ.២៦:៥)។**

ចំណុចដែលសំខាន់នោះគឺ ទោះព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកអ័ប្រាហាំជាយ៉ាងណា លោកអ័ប្រាហាំជឿដល់ព្រះបន្ទូល រួចហើយក៏អនុវត្តន៍តាមព្រះបន្ទូលដែលលោកជឿជាក់នោះ។ លោកអ័ប្រាហាំបានបញ្ចេញកិរិយាប្រព្រឹត្តិរបស់លោកដូចផ្នត់គំនិតដែលលោកជឿ។

សព្វថ្ងៃមានមនុស្សច្រើនណាស់ ដែលមិនអាចបញ្ចេញភ័ស្តុតាងអោយអ្នកផងឃើញថា ជំនឿមានឥទ្ធិពលនៅក្នុងជីវិតរបស់ខ្លួនសោះឡើយ។ ជំនឿមិនមែនគ្រាន់តែអង្គុយស្ងៀមមួយកន្លែង រួចហើយស្រមើស្រមៃថាជឿនោះទេ។ ពេលណាដែលលោកអ្នកជឿតាមព្រះជាម្ចាស់ លោកអ្នកប្រាកដជាបញ្ចេញសកម្មភាពជំនឿនោះស្របតាមសេចក្តីសន្យា ដែលញ៉ាំងអោយលោកអ្នកជឿនោះ។ បើប្រសិនណាជាមានបុគ្គលណាម្នាក់ចិត្តល្អ ហើយគេទូរស័ព្ទមកប្រាប់ខ្ញុំថា “លោកគ្រូខ្ញុំមានលុយចំនួនមួយពាន់ដុល្លាជូនលោកគ្រូ សូមលោកគ្រូអញ្ជើញមកយកចុះ!” តើលោកអ្នកបងប្អូនដឹងថា ខ្ញុំធ្វើដូចម្តេចទេ? ខ្ញុំដាក់តេឡេហ្វូនរួចហើយ ខ្ញុំអង្គុយមួយកន្លែង ហើយចេះតែស្រមើស្រមៃរីករាយទៅថា អ៊ូ! គេអោយលុយខ្ញុំហើយឬមួយយ៉ាងណា? បើសិនជាបងប្អូន ស្គាល់ខ្ញុំពិត

ប្រាកដ ខ្ញុំនឹងទំលាក់ការងារអ្វីទាំងអស់ ធ្វើដំណើរទៅយកលុយពីសប្បុរសជននោះសិន ហើយ។ ជំនឿត្រូវមានសកម្មភាពបញ្ជាក់ថា យើងពិតជាជឿមែន។ ជំនឿត្រូវបញ្ជាក់ ដោយទ្រង់ទ្រាយ និងខ្លឹមសារនៅក្នុងជីវិតមនុស្សដែលជឿនោះ ទើបសំអាងថាមនុស្ស នោះមានជំនឿមែន។ លោកអ័ប្រាហាំជឿដល់ព្រះជាម្ចាស់ ហើយដោយសារលោក ជឿដល់ព្រះអង្គទ្រង់បានរាប់លោកថាជាជនមានសេចក្ដីសុចរិតនៅចំពោះទ្រង់។ ពេល នេះព្រះជាម្ចាស់មានបន្ទូលទៅកាន់អ៊ីសាកទៀតហើយថា ព្រះជាម្ចាស់ចង់អោយអ៊ីសាក មានលក្ខណៈដូចឳពុកលោកដែរ។

## អ៊ីសាកគេចពីដំណើររបស់បិតា

**នោះអ៊ីសាក ក៏នៅក្នុងស្រុកកេរ៉ា (លោកុ.២៦:៦)។**

ស្រុកកេរ៉ាស្ថិតនៅម្តុំខាងត្បូងនៃប្រទេសកាណាន។ អ័ប្រាហាំនិងអ៊ីសាករស់ នៅក្នុងទឹកដីផ្នែកខាងត្បូង។ ជាក់ស្តែងអ័ប្រាហាំរស់នៅស្រុកមួយ ខាងជើងស្រុក ស៊ិគែម ប៉ុន្តែក្រោយមក លោកបានទៅរស់នៅស្រុកមួយស្ថិតនៅខាងត្បូងភូមិហេប្រុន ដែលជាកន្លែងលោកមានភាពជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់។

**ហើយមនុស្សនៅស្រុកនោះ គេសួរពីដំណើរប្រពន្ធគាត់ នោះគាត់ប្រាប់ថា គឺជាប្អូនខ្ញុំទេ ដ្បិតគាត់ខ្លាចមិនហ៊ានប្រាប់ថា ជាប្រពន្ធឡើយ ក្រែងមនុស្សស្រុកនោះសំឡាប់គាត់ដោយព្រោះរេបិកា ព្រោះនាងមានរូបស្រស់ល្អណាស់ (លោកុ.២៦:៧)។**

ត្រង់ចំណុចនេះ យើងឃើញលោកអ៊ីសាកបានធ្វើបាបដដែល ដូចឳពុកលោកបានប្រព្រឹត្តិពីមុនមកដែរ។ ព្រះជាម្ចាស់ហាមប្រាមដល់លោក មិនអោយចុះទៅប្រទេសអេស៊ីព្ទ ប៉ុន្តែលោកធ្វើដំណើរមកឯស្រុកកេរ៉ាវិញ។ នៅស្រុកកេរ៉ាមានមនុស្សប្រុសច្រើនណាស់សាក សួរពីដំណើរប្រពន្ធគាត់ឈ្មោះរេបិកានោះ។ លោកឆ្លើយត្រឡប់ទៅគេថា "នាងជាប្អូនខ្ញុំទេ"។ ការខុសគ្នារវាងលោកអ័ប្រាហាំ និងអ៊ីសាក គឺយ៉ាងដូច្នេះ លោកអ័ប្រាហាំបានភរតែពាក់កណ្តាលទេ ប៉ុន្តែអ៊ីសាកវិញ ភរសុីជាច់តែម្តង។

**កាលគាត់បាននៅស្រុកនោះជាយូរទៅ អ័ប៊ីម៉ាឡិច ស្តេចសាសន៍ភីលីស្ទីន ក៏ទតតាមបង្អួចមក ឃើញអ៊ីសាកកំពុងប្រឡែងនឹងរេបិកាជាប្រពន្ធ (លោកុ.២៦:៨)។**

ត្រង់ចំណុចនេះខ្ញុំយល់ថា អ៊ីសាកនិងរេបិកាប្រឡែងគ្នាលេងបែបប្តីនិងប្រពន្ធ។

**អ័ប៊ីម៉្មាឡិច ទ្រង់ហៅអ៊ីសាកមកសួរថា នេះប្រាកដជាប្រពន្ធអ្នកពិត ហេតុដូចម្តេចបានជាអ្នកនិយាយថា នាងជាប្អូនវិញដូច្នេះ រួចអ៊ីសាកទូលឆ្លើយថា ពីព្រោះទូលបង្គំនឹកខ្លាចក្រែងទូលបង្គំត្រូវស្លាប់ដោយព្រោះនាង អ័ប៊ីម៉្មាឡិចមានបន្ទូលតបថា អ្នកបានធ្វើអ្វីដល់យើងដូច្នេះ ក្រែងមានពួករាស្ត្រណាមួយបានរួមដំណេកជាមួយនឹងប្រពន្ធអ្នក យ៉ាងនោះនឹងនាំឱ្យយើងទាំងអស់គ្នាមានទោសដែរ (លោកុ.២៦:៩-១០)។**

ការដែលអ៊ីសាកបានភូតភរដល់អ្នកស្រុកនេះ បណ្តាលអោយអ្នកស្រុកនេះត្រូវទោសដោយសារអំពើបាប ដែលលោកអ៊ីសាកធ្វើដល់គេនោះ។ ដូច្នេះហើយ បានជាស្តេចអ័ប៊ីម៉្មាឡិចនិយាយមកកាន់អ៊ីសាកថា :

**រួចអ័ប៊ីម៉្មាឡិច ទ្រង់ហាមដល់រាស្ត្រទាំងអស់ថា អ្នកណាដែលពាល់មនុស្សនេះ ឬប្រពន្ធគាត់ នោះនឹងត្រូវសំឡាប់ជាពិត (លោកុ.២៦:១១)។**

ស្តេចអ័ប៊ីម៉្មាឡិច បានត្រឡប់ទៅជាមិត្តសម្លាញ់យ៉ាងស្និទ្ធស្នាលជាមួយនឹងអ៊ីសាក។ អ៊ីសាកទទួលការរាប់អានពីអ្នកស្រុកនោះណាស់ ដូចលោកអ័ប្រាហាំបាន

ទទួលការរាប់អានពីអ្នកស្រុកនោះដែរ។ បុរសទាំងពីររូបនេះ ជាបុរសដែលគួរអោយគោរព។ ខ្ញុំសុំនិយាយត្រង់ចំណុចនេះអោយហើយ ក្រែងលោទៅមុខ ខ្ញុំមិនបាននិយាយពីដំណើរលោកទាំងពីរម្តងទៀត។

## អ៊ីសាកនៅនៅស្រុកគេរ៉ា

**អ៊ីសាកគាត់ក៏សាបព្រោះនៅស្រុកនោះ ហើយនៅឆ្នាំនោះឯង គាត់បានផល១ជា១រយភាគឡើង ដោយព្រះយេហូវ៉ាទ្រង់ប្រទានពរឱ្យ (លោកុ.២៦:១២)។**

ត្រង់នេះ យើងឃើញថា ព្រះជាម្ចាស់ប្រទានពរដល់លោកអ៊ីសាក។ ព្រះពរដដែលនេះ ជាព្រះពរដែលព្រះជាម្ចាស់សន្យាដល់មនុស្សលោក ក្នុងសម័យដែលព្រះអង្គបានត្រាស់ហៅលោកអ័ប្រាហាំ។ ព្រះពរនោះ ជាព្រះពរដែលត្រូវខាងលោកីយ៍នេះ។ ព្រះអង្គសន្យាថា ពេលណាដែលគេទៅនៅលើដី ដែលព្រះអម្ចាស់ទ្រង់សន្យាថាអោយនោះព្រះអម្ចាស់ទ្រង់នឹងបំពេញជង្រុកជាលដោករបស់គេ ដោយសារម្ហូបអាហារយ៉ាងបរិបូរ។ ព្រះជាម្ចាស់បានធ្វើអោយសេចក្តីសន្យានោះ បានសម្រេចឡើងចំពោះអស់អ្នកណាដែលដើរយ៉ាងជិតស្និទ្ធជាមួយព្រះអង្គ។

សូមលោកអ្នកបងប្អូនចាំយ៉ាងដូច្នេះថា សេចក្ដីសន្យាប្រភេទនេះ មិនមែនយើងអាចទទួលបានជានិច្ចជាកាលនោះទេ។ ព្រះពរដែលយើងទទួលបានជានិច្ចជាកាលនោះ គឺជាព្រះពរខាងឯព្រលឹងវិញ្ញាណវិញ។

យើងឃើញថា លោកអ៊ីសាក បានទទួលពរពីព្រះអង្គយ៉ាងសម្បើម។

**គាត់ក៏ត្រឡប់បានជាអ្នកមាន ហើយចេះតែចំរើនជាច្រើនឡើង ទាល់តែមានយ៉ាងស្ដុកស្ដម្ភ (លោកុ.២៦:១៣)។**

សូមកុំអោយភ្លេចថា លោកអ៊ីសាកបានទទួលព្រះពរយ៉ាងច្រើនឥតគណនា។ ស្រែរបស់លោកបានបង្កើតផលមួយជាមួយរយភាគ។ ពេលដែលយើងសិក្សាអំពីជីវិតរបស់លោកអ័ប្រាហាំនិងលោកយ៉ាកុប យើងច្រើនតែយល់ច្រឡំថា ព្រះជាម្ចាស់មិនបានប្រទានពរអោយលោកអ៊ីសាកទេ។ តែតាមពិតទៅលោកអ៊ីសាកជាមនុស្សម្នាក់ដែលបានទទួលព្រះពរយ៉ាងឧដុង្គឧត្ដមមិនចាញ់ឪពុកនិងកូនលោកទេ។

យើងសង្កេតឃើញថា ជីវិតរបស់អ៊ីសាក ហើយនិងជីវិតរបស់លោកអ័ប្រាហាំបានត្បាញជាប់គ្នានៅក្នុងកីតែមួយ។ កំណើតរបស់លោកអ៊ីសាក ហើយនិងជីវិតរបស់ឪពុកលោក បានផ្សាភ្ជាប់ជាមួយនឹងបទពិសោធន៍ទាំងពួងរបស់លោកអ័ប្រាហាំ ពិសេសគឺត្រង់ដែលលោកអ័ប្រាហាំបានយកអ៊ីសាកទៅធ្វើជាយញ្ញបូជា។ លោកទាំងពីរបានរស់នៅជាមួយគ្នានៅក្នុងគ្រានោះ។ ហេតុអ្វីបានជាមានលក្ខណៈសំខាន់ត្រង់ថា លោកទាំង

ពីរបានរស់នៅជាមួយគ្នា? ចំណុចនេះ មានសារៈសំខាន់សម្រាប់យើង ពីព្រោះបទពិសោធន៍របស់លោកទាំងពីរបានបន្សល់ទុកនូវឧទាហរណ៍ សម្រាប់យើងស្ដីពីទំនាក់ទំនងរវាងព្រះវរបិតា ហើយនិងព្រះយេស៊ូវគ្រីស្ទ។ ទំនាក់ទំនងរវាងលោកអ័ប្រាហាំនិងអ៊ីសាកមានលក្ខណៈដូចជាទំនាក់ទំនងរវាងព្រះយេស៊ូវ និងព្រះវរបិតាសុទ្ធសាធ។ ត្រង់ចំណុចនេះហើយដែលព្រះយេស៊ូវមានបន្ទូលថា "...អ្នកណាដែលឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ..."(យ៉ូហាន១៤:៩)។ ក្នុងខ្លឹមសារកិច្ចការដែលព្រះអង្គទ្រង់សម្រេចធ្វើ ក្នុងនាមទ្រង់ជាសង្ឃដ៏ខ្ពស់បំផុត ព្រះអម្ចាស់យេស៊ូវមានបន្ទូលយ៉ាងដូច្នេះថា "...ទូលបង្គំបានបង្ហើយការដែលទ្រង់ប្រគល់មកឲ្យធ្វើ"(យ៉ូហាន១៧:៤)។ ស្ដីអំពីការងារដែលព្រះអម្ចាស់ទ្រង់ធ្វើរួមជាមួយព្រះវរបិតានោះ ព្រះយេស៊ូវមានបន្ទូលយ៉ាងដូច្នេះថា "...ព្រះវរបិតាខ្ញុំ ទ្រង់ធ្វើការដរាបមកដល់ឥឡូវនេះ ហើយខ្ញុំក៏ធ្វើការដែរ" (យ៉ូហាន៥:១៧)។ អាស្រ័យដោយហេតុដូច្នេះហើយបានជាខ្ញុំនិយាយថា ជីវិតរបស់លោកអ៊ីសាក និងលោកអ័ប្រាហាំបានត្បាញនៅក្នុងកីតម្បាញជាមួយគ្នាដូចជាជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតា។

ពេលនេះយើងឃើញថា លោកអ៊ីសាកអាចឈរបានដោយខ្លួនឯងហើយ ប៉ុន្តែលោកសម្ដែងខ្លួនលោកថា លោកមិនមែនជាមនុស្សល្អណាស់ណាទេ។ លោកបានសារភាពថា លោកមានភាពទន់ខ្សោយ ហើយក៏ប្រព្រឹត្តិអំពើបាបដែលដូចឪពុករបស់លោកបានប្រព្រឹត្តិពីមុនមកដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ព្រះបន្ទូលបានបញ្ជាក់អោយយើងដឹងច្បាស់លាស់ថា លោកអ៊ីសាកជនល្បីល្បាញម្នាក់ដែលរស់នៅក្នុងស្រុក

នោះដែរ។

**គាត់មានហ្វូងចៀម ហ្វូងគោ ហើយនឹងបាវបំរើជាច្រើន ឯពួកភីលីស្ទីនគេក៏កើតមានសេចក្តីច្រណែននឹងគាត់ (លោកុ. ២៦:១៤)។**

ដោយព្រោះលោកមានទ្រព្យសម្បត្តិច្រើនពេក បានជាពួកភីលីស្ទីនកើតមានសេចក្តីច្រណែនជាមួយនឹងគាត់។

**ហើយអណ្តូងទាំងប៉ុន្មាន ដែលពួកបាវរបស់ឪពុកគាត់បានជីកពីកាលដែលនៅរស់នៅឡើយ នោះពួកភីលីស្ទីនគេលុបដីពេញទាំងអស់ទៅ (លោកុ.២៦:១៥)។**

កាលលោកអ័ប្រាហាំនៅរស់នៅក្នុងស្រុកនោះ លោកជីកអណ្តូងជាច្រើន។ ក្រោយមកទៀត ពេលដែលកូនរបស់លោកបានទៅនៅស្រុកនោះវិញ គាត់ក៏ចាប់យកអណ្តូងទាំងអស់នោះមកជាកម្មសិទ្ធិរបស់លោក។ ប៉ុន្តែមានថ្ងៃមួយនោះ លោកបានក្រោកឡើងឃើញថា អណ្តូងទាំងនោះបានត្រូវគេលុបចោលអស់ទៅហើយ។ ពួកភីលីស្ទីនជាអ្នកដែលមកលុបអណ្តូងនោះចោល។ ត្រង់នេះយើងឃើញថា លោកមានទំនាស់ជាមួយពួកភីលីស្ទីន។ ទំនាស់ប្រទេសនេះ មានបន្តជានិច្ចរហូតមកដល់ជំនាន់ស្តេច

ជារីឌ។

**ស្ដេចអ័ប៊ីម៉្មាឡិច មានបន្ទូលនឹងអ៊ីសាកថា ត្រូវឱ្យអ្នកថយចេញពីយើងទៅ ពីព្រោះអ្នកពូកែជាងយើងហើយ (លោកុ.២៦:១៦)។**

ខនេះ សបញ្ជាក់អំពីជីវភាពរបស់អ៊ីសាកថា ជាអ្នកមានណាស់។

**អ៊ីសាកចេញពីទីនោះទៅដំឡើងត្រសាលត្រង់វាលច្រកកេរ៉ា ហើយក៏អាស្រ័យនៅឯនោះវិញ (លោកុ.២៦:១៧)។**

ស្ដេចអ័ប៊ីម៉្មាឡិចបានទូលទៅលោកអ៊ីសាកថា "ត្រូវឱ្យអ្នកថយចេញពីយើងទៅ ពីព្រោះអ្នកពូកែជាងយើងហើយ"។ ត្រង់នេះយើងឃើញថា ស្ដេចអ័ប៊ីម៉្មាឡិច គោរពលោកអ៊ីសាកជាខ្លាំង។ ពេលនេះ ឈានមកដល់ចំណុចដែលពីមុនយើងស្មានថា ជីវិតរបស់លោកអ៊ីសាកមានភាពទន់ខ្សោយណាស់ បែរមកជាមិនមែនដូច្នោះឡើយ។ ដោយសារមានទំនាស់បែបនោះ លោកត្រឡប់មកនៅឯទឹកដី ដែលឪពុកលោកបានតាំងទីលំនៅពីមុននោះវិញ។

**រួចគាត់ស្ដារអណ្ដូងទឹកទាំងប៉ុន្មាននោះ ដែលគេបានជីកនៅជាន់អ័ប្រាហាំជាឪពុកគាត់ឡើងវិញ ពីព្រោះពួកភីលីស្ទីនបានលុប**

**ទាំងអស់ក្រោយដែលអ័ប្រាហាំស្លាប់ទៅ រួចគាត់ដាក់ឈ្មោះអណ្តូងទាំងនោះ តាមឈ្មោះដែលឪពុកបានដាក់មកដែរ ពួកបាវរបស់អ៊ីសាកក៏ជីកអណ្តូង១ នៅក្នុងវាលច្រកនោះ បានទឹកដ៏ហូរហៀរ ឯពួកគង្វាលនៅស្រុកកេរ៉ា ក៏ប្រឈ្លោះគ្នានឹងពួកគង្វាលរបស់អ៊ីសាកថា ទឹកនេះជារបស់ផងយើង រួចគាត់ហៅអណ្តូងនោះថា អេសែក ពីព្រោះគេបានឈ្លោះនឹងគាត់**

**(លោកុ.១៨-២០)។**

ខគម្ពីរខាងលើសម្តែងថា ការឈ្លោះប្រកែកគ្នានោះ ចេះតែបន្តមានជាអាលជ្ជី។ ខ្ញុំចង់បញ្ជាក់ត្រង់នេះថា ទឹកគឺជាព្រះបន្ទូលរបស់ព្រះ។ យើងត្រូវផឹកព្រះបន្ទូលរបស់ព្រះដូចជាផឹកទឹក។ យើងហៅទឹកថា "ជាទឹកព្រះបន្ទូល" ហើយយើងផឹកព្រះបន្ទូល ពីព្រោះយើងចង់បំបាត់ការស្រេកឃ្លានរបស់ព្រលឹងយើង។ ទឹកព្រះបន្ទូលក៏សម្រាប់យកមកលាងសំអាតចិត្តទុច្ចរិតរបស់យើងដែរ។ ព្រះយេស៊ូវមានបន្ទូលថា យើងគ្រប់គ្នាអាចទទួលការលាងសំអាតបាន ដោយសារព្រះបន្ទូលរបស់ព្រះអង្គ ដែលទ្រង់មានបន្ទូលមកកាន់យើងរាល់គ្នា។

មិត្តសម្លាញ់អើយទឹកព្រះបន្ទូល ញ៉ាំងអោយជីវិតគ្រីស្ទបរិស័ទនៅក្នុងក្រុមជំនុំនីមួយៗមានភាពខុសគ្នា។ ពួកអ្នកជឿណា ដែលផឹកព្រះបន្ទូលរបស់ព្រះអោយបានឆ្អែត ជីវិតរបស់អ្នកនោះ មានភាពភ្លឺថ្លាជានិច្ចជាកាល។ សព្វថ្ងៃនេះ សង្គ្រាមមួយ

ដែលមានជានិច្ចនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ គឺមិនអាចមានពេលសិក្សាព្រះបន្ទូល អោយបានគ្រប់គ្រាន់។ សាតាំងតែងតែបណ្តោយអោយយើងធ្វើអ្វីទាំងអស់ វាមិនដែលឃាត់យើងទេ ប៉ុន្តែពេលណាយើងចាប់អានព្រះបន្ទូលព្រះអង្គ និងសិក្សាអោយបានជ្រៅជ្រះ នោះវាក៏បញ្ចេញសកម្មភាពឃាត់ឃាំងយើងភ្លាម។

**នោះក៏ជីកអណ្តូង១ទៀត ហើយគេឈ្លោះគ្នាពីអណ្តូងនោះដែរ រួចគាត់ហៅអណ្តូងនោះថា សិតនា គាត់ចេញពីទីនោះទៅជីកអណ្តូង១ទៀត តែឥតមានគេឈ្លោះគ្នាពីអណ្តូងនោះទេ បានជាគាត់ដាក់ឈ្មោះថា រេហូបូត ដោយនិយាយថា ឥឡូវនេះព្រះយេហូវ៉ាទ្រង់បានប្រទានឲ្យយើងបានទូលាយហើយ យើងនឹងបានចំរើនឡើងក្នុងស្រុកនេះ (លោកុ.២៦:២១-២២)។**

លោកដាក់ឈ្មោះអណ្តូងនេះថា រេហូបូត ពីព្រោះលោកយល់ថា ព្រះយេហូវ៉ាទ្រង់បាន ប្រទានអោយយើងបានទូលាយហើយ។ មុននឹងពេលបានទូលាយនេះ លោកជីកអណ្តូងនៅត្រង់ណា គេក៏មកដណ្តើមយកអណ្តូងត្រង់នោះទៅ។ លោកទៅជីកអណ្តូងមួយទៀត ក៏មានគេមកដណ្តើមយកអណ្តូងនោះបាត់ទៅទៀត។ លោកចេះតែបន្តលើកកញ្ចើទៅរកកន្លែងសុខខាងមុខទៀត។ ត្រង់នេះយើងសង្កេតឃើញថា លោកអ៊ីសាកជាមនុស្សពោរពេញទៅដោយសេចក្តីសុខនៅក្នុងចិត្ត ជាមនុស្សដែលមានសេចក្តី

អត់ធ្មត់ខ្លាំងណាស់។

## អ៊ីសាកឡើងទៅស្រុកបៀរ-សេបា

> **រួចគាត់ចេញពីទីនោះឡើងទៅឯបៀរ-សេបា ហើយនៅយប់នោះឯង ព្រះយេហូវ៉ាទ្រង់លេចមកឯគាត់មានបន្ទូលថា អញជាព្រះនៃអ័ប្រាហាំឪពុកឯង ដូច្នេះកុំឱ្យខ្លាចអ្វីឡើយ ពីព្រោះអញនៅជាមួយ ហើយនឹងឱ្យពរទាំងចំរើនពូជឯងឱ្យច្រើនឡើង ដោយព្រោះអ័ប្រាហាំជាអ្នកបំរើអញ (លោកុ.២៦:២៣-២៤)។**

ត្រង់នេះយើងឃើញព្រះជាម្ចាស់បានយាងមកដើម្បីនឹងល្បួងលោមចិត្តលោក។

> **រួចគាត់ស្អាងអាសនា១នៅស្រុកនោះ ក៏អំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា គាត់ដំឡើងត្រសាលនៅទីនោះហើយពួកបាវគាត់ក៏ជីកអណ្តូង១ នៅកន្លែងនោះដែរ (លោកុ.២៦:២៥)។**

មកដល់ស្រុកនេះ លោកអ៊ីសាកក៏ជីកអណ្តូងជាច្រើនទៀត។ កាលណាលោកអ្នកនិយាយអំពីឈ្មោះអ៊ីសាក លោកអ្នកតែងតែចាំជានិច្ចអំពីអណ្តូងរាប់រយ។

**ឯអ័ប៊ីម៉្មាឡិច អ័ហ៊្សាតជាសំឡាញ់ទ្រង់ នឹងភីកុលជាមេទ័ព ទ្រង់ក៏ចេញពីកេរ៉ាទៅឯគាត់នោះអ៊ីសាកសួរថា ហេតុអ្វីបាន ជាមកឯទូលបង្គំ ដ្បិតទ្រង់ស្អប់ទូលបង្គំហើយ បានទាំងបណ្តេញ ទូលបង្គំចេញផង គេឆ្លើយតបថា យើងបានឃើញជាក់ច្បាស់ថា ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងអ្នក បានជាយើងបាននិយាយគ្នា ថា គួរឱ្យយើងតាំងសម្បថចំពោះគ្នាទៅវិញទៅមកឥឡូវ យើង សូមតាំងសញ្ញានឹងអ្នកថា អ្នកនឹងមិនធ្វើអាក្រក់ដល់យើងឡើយ ដូចជាយើងក៏មិនបានពាល់ដល់អ្នកដែរ គឺយើងបានប្រព្រឹត្ត ចំពោះតែសេចក្តីណា ដែលល្អដល់អ្នកប៉ុណ្ណោះ យើងបានឱ្យអ្នក ចេញមកដោយសេចក្តីសុខសាន្ត ឥឡូវនេះអ្នកជាមនុស្សមាន ព្រះពរនៅចំពោះព្រះយេហូវ៉ា (លោកុ.២៦:២៦-២៩)។**

បើយើងសង្កេតមើលតែមួយភ្លែត យើងហាក់ដូចជាឃើញថា លោកអ៊ីសាក មានភាពទន់ខ្សោយណាស់។ ប៉ុន្តែផ្ទុយទៅវិញ សូម្បីស្តេចអ្នកស្រុកកេរ៉ា ក៏បានធ្វើ ដំណើរតាមលោកអ៊ីសាករហូតដល់បៀរ-សេបា ដើម្បីស្តារមិត្តភាពជាមួយលោកឡើង វិញ។ ត្រង់នេះ យើងឃើញថា ឥទ្ធិពលរបស់លោក អ៊ីសាក នៅក្នុងស្រុកនោះ មិនមែន ចុះថយឡើយ។

**ឯអេសាវកាលគាត់យកនាងយូឌីត ជាកូនបេរី សាសន៍ហេត ហើយនាងបាសម៉ាតជាកូនអេឡូនសាសន៍ហេតធ្វើជាប្រពន្ធ នោះគាត់មានអាយុ៤០ឆ្នាំហើយ នាងទាំង២នោះ ក៏នាំឱ្យអ៊ីសាក ហើយនឹងរេបិកាពីបាកចិត្តណាស់ (លោកុ.២៦:៣៤-៣៥)។**

នៅក្នុងជំពូកបន្ទាប់ទៅទៀត លោកអ្នកបងប្អូននឹងឃើញពណ៌ពិតប្រាកដរបស់លោកយ៉ាកុប ថាមានលក្ខណៈបែបណាហើយ។ ទំរាំដល់ពេលនោះ សូមរង់ចាំស្តាប់រឿងនេះជាបន្តទៅទៀត។